# អំពីពាក្យ «សង្ក្រាន្ត» និង «មហាសង្ក្រាន្ត»

មុនដែលប្រជាជនខ្មែរបានឮ បានស្គាល់អំពីអង្គរសង្ក្រាន្ត ឬសង្ក្រាន្តផ្សេងៗ យើងធ្លាប់ឮតែពាក្យ "មហាសង្ក្រាន្ត" បើទោះបីជាតាមរយៈបទចម្រៀងក្ដី ឬតាមឯកសារផ្សេងៗក្ដី[1]។ តើ "សង្ក្រាន្ត" និង "មហាសង្ក្រាន្ត" ខុសគ្នាឬទេ?

ជាដំបូង យើងនាំគ្នាពិនិត្យមើលប្រភពឯកសារដែលយើងនិយមប្រើប្រាស់ទាំងអស់គ្នាជាមុនសិន។ វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ បានបង្ហាញថា «សង្ក្រាន្ត» ជាពាក្យមកពីសំស្រ្កឹតថា «សង្ក្រាន្តិ» មានន័យថា "ដំណើរឃ្លាតចាកទី; ការឈានចូលដល់; ដំណើរដែលព្រះអាទិត្យចរចូលដល់ទីចួបមួយជុំរាសចក្រ គឺដំណើរដែលដើមនិងចុងនៃរាសិចក្រចួបគ្នា ពេញគ្រប់ជាមួយឆ្នាំ (ដំណើរដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី), ពិធីចូលឆ្នាំថ្មី(សង្ក្រាន្តមានបីថ្ងៃគឺ ថ្ងៃទី១ ជាថ្ងៃចូលឆ្នាំ, ថ្ងៃទី២ ជាពារកណ្ដាល ឬហៅថា វ័នបត(ថ្ងៃខ្វាក់), ថ្ងៃទី៣ ជាពារឡើងស័ក គឺផ្លាស់ស័កថ្មីនៅថ្ងៃនេះឯង[2]។

គួរកត់សម្គាល់ថា ពាក្យ «សង្ក្រាន្ត» ក្ដី ក៏ដូចជាពិធីទាក់ទងនឹង «សង្ក្រាន្ត» ក្ដី គឺទទួលឥទ្ធិពលពីឥណ្ឌា។ ដូច្នេះជាបន្ទាប់ យើងត្រូវទៅមើលឥណ្ឌាម្ដង។ ក្នុងភាសាសំស្ក្រឹត ពាក្យ «សង្ក្រាន្ត» មកពីបុព្វបទ «សំ» (ជាមួយ) + «ក្រាន្ត» (ឈានហើយ) មានន័យថាឆ្លងពីមួយទៅមួយ ឈានពីកន្លែងមួយទៅកន្លែងមួយ។ ចំណែកនៅក្នុងតារាសាស្រ្ត «សង្ក្រាន្ត» ឬ «សង្ក្រាន្តិ» សំដៅដល់ដំណើរផ្លាស់ទីរបស់ព្រះអាទិត្យ ពីរាសីមួយទៅកាន់រាសីមួយទៀត[3]។ ល្វែងរបស់រាសីមួយមានគម្លាត៣០អង្សា នាំឱ្យគេចែក «សង្ក្រាន្ត» នេះចែកជា១២ តាមរាសីទាំង១២នោះដែរ។ ដូច្នេះ មួយជុំល្វែងរាសី មាន៣៦០អង្សា។ តាមជំនឿនិងហេតុ

---

[1] នៅក្នុងអត្ថបទនេះពុំនិយាយដល់រឿងពាក្យ «សង្ក្រាន្ត» ក្នុងពិធី "ត្រស្ដិសង្ក្រាន្ត" ទេ។ សេចក្ដីទាក់ទងនឹងពិធី «ត្រស្ដិសង្ក្រាន្ត» នឹងមានបង្ហាញជូននៅអត្ថបទក្រោយ។

[2] វចនានុក្រមខ្មែរ ភាគ២, ១៩៦៨: ៩២៦។

[3] Monier, 1872: 1127។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

ផលដោយឡែកពីគ្នា ប្រជាជននៅតំបន់ផ្សេងៗគ្នា បានជ្រើសរើសយក «សង្ក្រាន្តិ» ណាមួយក្នុងចំណោម១២ ដើម្បីប្រារព្ធពិធីចូលឆ្នាំ។ នៅប៉ែកខ្លះនៃប្រទេសឥណ្ឌា គេជ្រើសរើសយក «មករសង្ក្រាន្តិ»[4] ដើម្បីប្រារព្ធពិធីចូលឆ្នាំនិងមានពិធីបង្ហោះខ្លែងផងដែរ។ កន្លែងខ្លះជ្រើសរើស កក៌ដាសង្ក្រាន្ត[5] ឬធ្នូសង្ក្រាន្ត[6] ដើម្បីប្រារព្ធពិធីចូលឆ្នាំ។ នៅភាគខ្លះនៅឥណ្ឌានិងដែនអាស៊ីអាគ្នេយ៍ គេជ្រើសរើស «មេសរាសី» ឬ «មេសសង្ក្រាន្ត» ដើម្បីប្រារព្ធពិធីចូលឆ្នាំ ដោយយល់ថាពេលនោះថ្ងៃនិងយប់មានរយៈពេលស្មើគ្នា។ ដូច្នេះយើងឃើញថា ពាក្យ «សង្ក្រាន្ត» ឬពាក្យ «សង្ក្រាន្តិ» មិនមែនជាពាក្យកំណត់ថាជាពេលចូលឆ្នាំនោះឡើយ ដ្បិតក្នុងមួយឆ្នាំមាន១២សង្ក្រាន្តឯណោះ។

បើមើលតាមរយៈឯកសារសិលាចារឹកវិញ កាលពីបុរាណពាក្យនេះមានសំណេរបីបែបគឺ «សំក្រាន្ត, សង៑ក្រាន្ត និងសង្ក្រាន្ត»។ ពាក្យ "សង្ក្រាន្ត" ដែលចាស់ជាងគេទំនងមានក្នុងសិលាចារឹកប្រាសាទភិមានអាកាស K.291 ផ្ទាំងខាងជើង បន្ទាត់ទី៣១-៣២ ចារនៅ៨៣២មហាសករាជត្រូវនឹងឆ្នាំ៩១០គ.ស. ក្នុងរាជ្យព្រះបាទហស៌វម៌្មទី១ នៅត្រង់ចំណុចរៀបរាប់ពីដង្វាយប្រចាំថ្ងៃសង្ក្រាន្ត។ ទោះបីជាសំណេរបែបណាមួយក៏ដោយ ក៏ពាក្យនេះពុំបង្ហាញពីការចូលឆ្នាំនោះឡើយ ប៉ុន្តែសំដៅដល់ការផ្លាស់រាសីមួយចូលរាសីមួយទៀតប៉ុណ្ណោះ។ សិលាចារឹកប្រាសាទបេង K.989 បានរៀបរាប់ពីដង្វាយសម្រាប់ថ្ងៃពិសេសៗដូចមានឃ្លាថា [...*សូយ៌្យគ្រាស ចន្ទ្រគ្រាស សង្ក្រាន្ត បញ្ចោត្សវ មហោត្សវ តិថិវិគេបណេកល្បនាតបុរោហិតចន្ទ្យក៑ផ្លាសិយោ១ ទក្សិណាស្រូវជេ១ បុរោហិតវ្លែប្វរចន្ទ្យក៑ផ្លាសិវ្វះ១ ទក្សិណាស្រូវជេ១*...] មានសេចក្ដីសម្រួលថា "(រៀងរាល់)ថ្ងៃសូរ្យគ្រាស ចន្ទ្រគ្រាស សង្ក្រាន្ត បញ្ចោត្សវ(បុណ្យទាំង៥ប្រចាំឆ្នាំ) មហោត្សវ(បុណ្យធំ) ថ្ងៃពិសេស ត្រូវរៀបដង្វាយគ្រូដល់

---

[4] សង្ក្រាន្តខែមករា។

[5] សង្ក្រាន្តខែកក្កដា។

[6] សង្ក្រាន្តខែធ្នូ។

បុរោហិតមានសម្បៀកផ្ទាស់១យៅ ដង្វាយបូជាជាស្រូវ១ជើ ដង្វាយគ្រូដល់បុរោហិតវៃស្ណវៈ មានសម្បៀកផ្ទាស់១បន្ទាស់ ដង្វាយបូជាជាស្រូវ១ជើ...”។ ចំណែកឯសិលាចារឹកភ្នំសណ្ដក K.195 សរសេរថា [...*មនិច្ចេអាគ្រមបិទុកចំនាំតកម្រតេងជគតិវ្រះ ចរុលិះ១ប្រតិទិន សង្ក្រាន្តជេ១*...] ដែលមានសេចក្ដីសម្រួលថា “(កាល)ធ្វើអាស្រម គប្បីថ្វាយគ្រឿងដង្វាយដល់ព្រះមានព្រះចរុ១លិះ ប្រចាំថ្ងៃសង្ក្រាន្ត១ជើ...”។

ឥឡូវយើងមកមើលសិលាចារឹកដែលមានប្រើពាក្យ «សង្ក្រាន្ត» ដែលភ្ជាប់ជាមួយកាលបរិច្ឆេទម្ដង។ សិលាចារឹកទេពប្រណម្យ K.290 សរសេរថា [*៩២៧គកវ្យរិកេតិវៃគាខ សនៃក្ខរវារសង្ក្រាន្ត*...] មានសេចក្ដីសម្រួលថា "ឆ្នាំ៩២៧នៃមហាសករាជ ២កើត ខែពិសាខ ថ្ងៃសៅរ៍ ថ្ងៃសង្ក្រាន្ត"។ សិលាចារឹក K.391សរសេរថា [... *១០០៤គកបូណ៌មីកត្តិកក្ធតិកាប្ក្បសង្ក្រាន្តគុក្រវារ*...] ដែលមានសេចក្ដីសម្រួលថា "ឆ្នាំ១០០៤មហាសករាជ ថ្ងៃពេញបូណ៌មី ខែកត្តិក ឫក្សកតិកា ថ្ងៃសង្ក្រាន្ត ថ្ងៃសុក្រ..."។ សិលាចារឹក K.392 ពុំមានចុះឆ្នាំបរិច្ឆេទ ប៉ុន្ដែមានខែថ្ងៃដូចក្នុងសេចក្ដីថា [...*ត្រយោទគិកេតមាគ៌គិរសៅវារសង្ក្រាន្ត*...] ដែលមានសេចក្ដីសម្រួលថា "ថ្ងៃទី១៣កើត ខែមិគសិរ ថ្ងៃសៅរ៍ ថ្ងៃសង្ក្រាន្ត"។ ចំណែកឯសិលាចារឹកកំផែងណៃ K.374 មានប្រើពាក្យដែលគួរឱ្យចាប់អារម្មណ៍គឺ “វិមុវសំក្រាន្ត” ដែលសម្គាល់ដល់វេលាដែលយប់និងថ្ងៃមានពេលស្មើគ្នា។ សិលាចារឹកនោះសរសេរថា [*៩៦៤គក វ្យរិកេតិចៃត្រវិមុវសំក្រាន្ត*...] ដែលមានសេចក្ដីសម្រួលថា “ឆ្នាំ៩៦៤មហាសករាជ ពីរកើត ខែចេត្រ ថ្ងៃវិសុវសង្ក្រាន្ត”។

តាមរយៈការបង្ហាញខាងលើ យើងឃើញថាកាលដើមឡើយខ្មែរយើងពុំបានប្រើពាក្យ “សង្ក្រាន្ត” ដើម្បីសម្គាល់ថ្ងៃចូលឆ្នាំនោះឡើយ។ បើយើងយល់ថាពាក្យ «សង្ក្រាន្ត» ដែលមានភ្ជាប់នឹងកាលបរិច្ឆេទខាងលើត្រូវគ្នានឹងចូលឆ្នាំនោះ ហេតុអ្វីក៏ម្ដងចូលឆ្នាំខែនេះម្ដងចូលឆ្នាំខែនោះទៅវិញ? ដូចបានជម្រាបមកហើយថា ពាក្យនេះគ្រាន់តែសំដៅដល់

ការដូរពាសីតាមតារាសាស្ត្រប៉ុណ្ណោះ។ បន្ថែមពីនេះ ក៏ដូចជាគ្មានឯកសារសិលាចារឹកណាមួយនិយាយពីរឿងចូលឆ្នាំនេះដែរ។

ឥឡូវយើងមកមើលពាក្យ "មហាសង្ក្រាន្ត" វិញម្តង។ ពុំមានឯកសារតាមរយៈសិលាចារឹកនិយាយពីពាក្យនេះឡើយ។ ប៉ុន្តែយើងឃើញមានឯកសារចាស់ៗមួយចំនួនបានបង្ហាញពីពាក្យនេះ ដូចជាសៀវភៅ «សូរ្យយាត្រឡើងស័ក-ប្រក្រតិទិន» ឬសៀវភៅ «មហាសង្ក្រាន្ត» តាមឆ្នាំនីមួយៗជាដើម ដែលមានចេញផ្សាយជារៀងរាល់ឆ្នាំ។ បើគិតតាមការពន្យល់ខាងលើ យើងអាចយល់បានយ៉ាងងាយអំពីពាក្យនេះ ហើយហេតុអ្វីចាស់បុរាណប្រើពាក្យនេះ។ «មហា» មានន័យយ៉ាងសាមញ្ញថា «ធំ»។ ដូច្នេះ "មហាសង្ក្រាន្ត" មានន័យថាសង្ក្រាន្តធំ។ ហេតុអ្វីគេបានជាធំ? ដ្បិតគេកំណត់ថាថ្ងៃសង្ក្រាន្តណាដែលរាប់ថាជាថ្ងៃឆ្លងឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី គឺរាប់ថាជា «មហាសង្ក្រាន្ត» ហើយ។ ពាក្យ «មហាសង្ក្រាន្ត» ហាក់ចាប់ផ្តើមសាបបន្តិចម្តងៗពីសង្គមខ្មែរ ម្យ៉ាងដោយសារមានការជំនួសដោយព្រឹត្តិការណ៍ធំៗនានា នៅពេលចូលឆ្នាំក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

## បញ្ជីរូបភាព



សិលាចារឹកភ្នំរ៉ាន K.392

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សិលាចារឹកទេពប្រណម្យ K. 290



សិលាចារឹកភ្នំរ៉ាន K. 391



សិលាចារឹកកំផែងណៃ K.374



សករាជ

សករាជជាកំណត់រាប់ចំនួនឆ្នាំ គឺមួយឆ្នាំសករាជឡើង ១ សករាជឆ្នាំចាស់នឹងសករាជឆ្នាំថ្មី ផ្លាស់គ្នាត្រង់ថ្ងៃឡើងស័កនៅម៉ោងវេលាដែលហោរាចុះក្នុងមហាសង្ក្រាន្ត តែវេលាត្រង់ផុតសករាជឆ្នាំចាស់ដល់មកជារៀយ ៗ ខុសវេលាត្រង់វេលាថ្ងៃបែកគ្នា គឺកម្រត្រូវត្រង់វេលាអធ្រាត្រដែលជាទីបំផុតថ្ងៃនោះឯងហេតុនោះលោកឲ្យរាប់ថ្ងៃទី ១ ក្នុងសករាជឆ្នាំថ្មី នៅថ្ងៃពីមុខថ្ងៃឡើងស័កតទៅ ព្រោះពុទ្ធសករាជក្ដី មហាសករាជក្ដី ចុល្លសករាជក្ដី បោរាណសករាជក្ដី សឹងរាប់ដូចគ្នា ។

ឯពុទ្ធសករាជដែលព្រះសង្ឃទាំងឡាយ សូត្រសព្វថ្ងៃនេះបើពុំបានពិចារណា ហាក់ដូចមានពីរយ៉ាង ព្រោះព្រះសង្ឃយក

*អត្ថបទក្នុងសៀវភៅ «សូរ្យយាត្រឡើងស័ក-ប្រក្រតិទិន» របស់លោក ពូវ អ៊ុម*

## ឯកសារយោង

*ពុទ្ធសាសនបណ្ឌិត្យ*

*១៩៦៨. វចនានុក្រមខ្មែរ ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។*

Williams, M.

1872. *A Sanskrit-English Dictionary: Etymologically and philologically arranged with special reference to Greek, Latin, Gothic, German, Anglo-Saxon, and other cognate Indo-European Languages*. At the Clarendon Press Sold by Macmillan.

*អត្ថបទដោយ៖ ហ៊ិន ឈុនតេង*